ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ..........

# សេចក្តីប្រកាសព័ត៌មាន
# អ្នកនាំពាក្យក្រសួងការពារជាតិ

តបតាមការអញ្ជើញរបស់ នាយឧត្តមសេនីយ៍ វ៉ៃ ហ្វេនហេ (WEI FENGHE) សមាជិកក្រុមប្រឹក្សារដ្ឋ និង ជារដ្ឋមន្ត្រីក្រសួងការពារប្រទេស សាធារណរដ្ឋប្រជាមានិតចិន សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា នឹងដឹកនាំគណៈប្រតិភូយោធាជាន់ខ្ពស់កម្ពុជា អញ្ជើញទៅ បំពេញទស្សនកិច្ចផ្លូវការ និងចូលរួមវេទិកា "8Th Beijing Xiangshan Forum" នៅទីក្រុងប៉េកាំង សាធារណរដ្ឋ ប្រជាមានិតចិន ចាប់ពីថ្ងៃទី២២ ដល់ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨។

វេទិកា Xiangshan ប៉េកាំង លើកទី៨ (8Th Beijing Xiangshan Forum) ត្រូវបានរៀបចំឡើងក្រោម ប្រធានបទ "ការកសាងសមភាព និងការជឿទុកចិត្តគ្នាទៅវិញទៅមក ទំនាក់ទំនងភាពជាដៃគូសន្តិសុខថ្មីមួយនៃ កិច្ចសហប្រតិបត្តិការឈ្នះឈ្នះ" ដែលនឹងផ្តោតលើការពិភាក្សាផ្លាស់ប្តូរពីវិធីសាស្រ្តថ្មី ទស្សនៈថ្មីនៃការគ្រប់គ្រង សន្តិសុខអន្តរជាតិ ការគំរាមកំហែង និងការទប់ទល់នឹងភេរវកម្ម រួមទាំងកិច្ចសហប្រតិបត្តិការ និងបញ្ហាប្រឈម មួយចំនួនទៀត។

វេទិកានេះ នឹងមានការអញ្ជើញចូលរួម ដោយថ្នាក់ដឹកនាំយោធា និង ក្រសួង ស្ថាប័នការពារជាតិ ជិត ១០០ប្រទេស មកពីតំបន់អាស៊ីប៉ាស៊ីហ្វិក អឺរ៉ុប ទ្វីបអាហ្វ្រិក អាមេរិកឡាទីន ព្រមទាំងអង្គការអន្តរជាតិ អ្នកប្រាជ្ញ អ្នកជំនាញ បញ្ញវន្តល្បីៗ ផងដែរ៕

ថ្ងៃអាទិត្យ ១២កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៨